# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សារលិខិតជូនពរ

## សូមគោរពជូន សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
## នៃព្រះរាជាណាចក្រកម្ពុជា

***សម្តេចជាទីគោរពដ៏ខ្ពង់ខ្ពស់!***

នាឱកាសដ៏មហានក្ខត្តឫក្សវិសេសវិសាល និងជាមហាកិត្តិយសដ៏ឧត្តុង្គឧត្តមបំផុត ដែល**សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានទទួលនូវ **ពានរង្វាន់សន្តិភាព និងការអភិវឌ្ឍ** ពីសហព័ន្ធប្រព័ន្ធផ្សព្វផ្សាយអាស៊ាន នាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦ ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ យើងខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង និងសូមសម្តែងនូវអំណរសាទរប្រកបដោយក្តីរំភើបរីករាយជាទីបំផុតគោរពជូនចំពោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ដែលនេះមិនត្រឹមតែជាមហាកិត្តិយសដ៏ឧត្តុង្គឧត្តមថ្លៃថ្លារបស់សម្តេច និងក្រុមគ្រួសារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមោទកភាពរបស់ប្រជាជន និងប្រជាជាតិខ្មែរថែមទៀតផង។

**ពានរង្វាន់សន្តិភាព និងការអភិវឌ្ឍ** ដែលត្រូវបានប្រគល់ជូន **សម្តេចតេជោនាយករដ្ឋមន្ត្រី** នាពេលនេះគឺពិតជាស័ក្តិសមបំផុតចំពោះគំរូវីរភាព និងគុណបំណាច់ដ៏ថ្លៃថ្លារបស់សម្តេចក្នុងនាមជាអគ្គមគ្គុទេសក៏ដ៏ឆ្នើមក្នុងការដឹកនាំប្រកបដោយភាពឈ្លាសវៃ និងគតិបណ្ឌិត តស៊ូរំដោះប្រទេសជាតិឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ កសាងសុខសន្តិភាព កសាងខឿនការពារជាតិ ការពារបូរណភាពទឹកដីកម្ពុជា ការអនុវត្តនយោបាយ "ឈ្នះ-ឈ្នះ" សម្រេចបានការឯកភាពជាតិ ផ្សះផ្សារជាតិ បង្រួបបង្រួមជាតិ កំណែទម្រង់ស៊ីជម្រៅ និងការអភិវឌ្ឍប្រទេសជាតិឱ្យបានរីកចម្រើនលើគ្រប់វិស័យ។

យើងខ្ញុំទាំងអស់គ្នា ពិតជាមានមោទកភាពជាទីបំផុត និងសូមយកឱកាសដ៏មហាប្រសើរថ្លៃថ្លានេះ បួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបីវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា សូមជួយប្រសិទ្ធពរជ័យ បវរសួស្តី សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការជូនដល់ **សម្តេចតេជោនាយករដ្ឋមន្ត្រី និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ព្រមទាំងក្រុមគ្រួសារ** សូមបានសម្រេចប្រកបនូវសុខភាពល្អបរិបូរណ៍ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីដឹកនាំ និងអភិវឌ្ឍមាតុភូមិកម្ពុជា ក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមបម្រើជាតិ និងប្រជាជនកម្ពុជា ឱ្យកាន់តែរីកចម្រើនឈានឆ្ពោះទៅរកភាពរុងរឿងសំបូរសប្បាយជានិច្ចនិរន្តរ៍។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្រ និងអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែមីនា ឆ្នាំ២០១៦

**តំណាងមន្ត្រីរាជការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩